# របាយការណ៍
# ស្តីពី

# គម្រោងសំរាប់ការគាំទ្រ និងជំរុញគំនិតផ្តួចផ្តើមថ្មីនៅក្នុងមូលដ្ឋាន
# ប្រធានបទ

# បច្ចេកទេសដាំដុះដំណាំពោតស ដោយគំនិតផ្តួចផ្តើមថ្មីរបស់កសិករ

# ខេត្តស្វាយរៀង

ការពិសោធន៍ ស្រាវជ្រាវ ដោយគំនិតផ្តួចផ្តើមថ្មីរបស់កសិករលើបច្ចេកទេសដាំដុះដំណាំពោតស
នៅ ឬស្សីអម ឃុំ ខ្សែត្រ ស្រុក កំពង់រោទិ៍ ខេត្តស្វាយរៀង

**១-សេចក្តីផ្តើម**

នៅប្រទេសកម្ពុជា ជាប្រទេសមួយដែលសំបូរទៅដោយធនធានធម្មជាតិ និងមានអាកាសធាតុ អំណោយផល សមស្របនិងការដាំដុះដំណាំ និង ដីសំបូរទៅដោយជីជាតិ និងមានភ្លៀងធ្លាក់បានល្អ ។ ហើយកសិករភាគច្រើនប្រកបមុខរបរលើវិស័យកសិកម្មដូចជាការធ្វើស្រែ -ការដាំឈើហូបផ្លែ-ការចិញ្ចឹមសត្វ និងការដាំដំណាំរួមផ្សំគ្រប់មុខ។ល។ ដែលទាំងអស់នេះហើយ ដែលជួយបង្កើនប្រាក់ចំណូលដល់គ្រួសារ របស់គាត់ និងធ្វើឲមានស្បៀងហូបគ្រប់គ្រាន់ និងមានសុខភាពល្អ ។ ជាការពិតណាស់ហើយ វិស័យកសិកម្ម មិនគ្រាន់ តែបង្កើនប្រាក់ចំណូលនៅក្នុងគ្រួសារនោះទេ គឺថែមទាំងជួយអោយសេដ្ឋកិច្ចរបស់ជាតិយើងមាន ការរីកចំរើន ថែមទាំងធ្វើអោយសេដ្ឋកិច្ចគ្រួសារ ធូធារផងដែរមិនតែ ប៉ុណ្ណោះធ្វើអោយកសិករមានការងារ ធ្វើនិងកាត់បន្ថយអំពើហឹង្សានៅក្នុងគ្រួសារ ។ យើងដឹងហើយថាកសិករយើងមួយចំនួននៅមានបច្ចេកទេស កសិកម្មនៅមានកំរិតនៅឡើយ ។ ហើយកសិករមួយចំនួនមានការសិក្សា ពិសោធន៍ចេះបច្ចេកទេសដោយ ខ្លួនគាត់ផ្ទាល់តាមរយះពីដូនតារបស់គាត់ ហើយទទួលទិន្នផលទាបមិនគ្រប់គ្រាន់ទៅតាមតំរូវការនិងកសិករ មួយចំនួនមានការធ្វើការដាំដុះដោយគំនិតឆ្នៃប្រឌិតនិងធ្វើការពិសោធន៍ដោយខ្លួនគាត់ផ្ទាល់ហើយនៅពេលបានទទួលបានលទ្ធផលល្អប្រសើរគាត់មិនបានធ្វើការចងក្រងជាឯកសារ និងផ្សព្វផ្សាយដល់កសិករនៅក្នុងមូលដ្ឋានរបស់គាត់ និងមិនមានការចងក្រង ជាឯកសារបច្ចេកទេស ។

## ២-មូលហេតុសិក្សា

ដោយយល់ឃើញថា កសិករជាអ្នកអនុវត្តន៍លើការងារកសិកម្ម ហើយគាត់ជាអនុវត្តន៍ទៅតាម ទំលាប់របស់គាត់ម្យ៉ាងវិញទៀតកសិករមួយចំនួនមានគំនិតចង់ធ្វើការពិសោធន៍តែគាត់មិនហ៊ានសាកល្បងព្រោះខ្លាចទទួលបរាជ័យនិងខាតបង់ថវិការនិងពេលវេលារបស់គាត់ ។

ហេតុដូចនេះ ទើបមានកម្មវិធីប្រ្វលីណូវ៉ាកម្ពុជាបានជួយឧត្ថម្ភថវិការគាំទ្រនិងបានសហាការណ៍ជាមួយមន្ត្រីកសិកម្មខេត្តស្វាយរៀង ដើម្បីចុះសិក្សាជ្រើសរើសកសិករស្មគ្រ័ចិត្ត ធ្វើពិសោធន៍ស្រាវជ្រាវ និងតាមគំនិតគំនិតឆ្នៃប្រឌិតដោយខ្លួនគាត់ផ្ទាល់ និងស្រាវជ្រាវតាមគំនិតរបស់កសិករដែលចង់បាន ដោយមានការសម្របសម្រួល ពីបច្ចេកទេស មន្ត្រីបច្ចេកទេសកសិកម្ម ជាអ្នកជួយសំរបសំរួល បច្ចេកទេស និងមានការគាំទ្រដោយ កម្មវិធីប្រលីណូវ៉ា។

## ៣-ទំហំនៃការសិក្សា

ការធ្វើពិសោធន៍នេះមានរយៈពេលវេលាអាស្រ័យទៅលើការរៀបចំ និងពេលវេលារបស់គាត់ក្នុងអំពេលគាត់ទទួលបានថវិការរៀបចំពិសោធន៍ ពីកម្មវិធីប្រលីណូវ៉ា ដើម្បីរៀបចំ ពូជ , សំភារៈ , ទីកន្លែងធ្វើពិសោធន៍ និងធនធានផ្សេងៗនិងអ្នកសំរបសំរួលចុះតាមដានការអនុវត្តន៍និងផ្តល់ការណែនាំបន្ថែម។

ដូចនេះការធ្វើពិសោធន៍ស្រាវជ្រាវ ដោយគំនិតឆ្នៃប្រឌិតរបស់គាត់ ផ្តោតតែទៅលើគ្រួសារកសិករដែលមានចំណង់ចំណូលចិត្តនិងស្មគ្រ័ចិត្តចូលរួមធ្វើពិសោធន៍ និងជាកសិករឧស្សាហ៍ព្យាយាម មានគំនិតផ្តួចផ្តើមឆ្នៃប្រឌិត និងមាន ចំនង់ចំណូលចិត្តស្រាវជ្រាវធ្វើពិសោធន៍ និងជាកសិករមានផ្ទៃដីធ្វើពិសោធន៍ សមស្រប ជាពិសេសកំលាំង ពលកម្ម និងធនធានសម្ភារៈមួយចំនួន។ ការធ្វើពិសោធន៍នេះជ្រើសរើសកសិករ នៅក្នុងភូមិ ឬស្សីអម ឃុំខ្សែត្រ ស្រុកកំពង់រោទ៌ ខេត្តស្វាយរៀង។

## ៤-គោលបំណង

ធ្វើការពិសោធន៍ស្រាវជ្រាវដោយគំនិតផ្តួចផ្តើមបច្ចេកទេសដោយខ្លួនគាត់

សិក្សាស្វែងយល់ពីស្ថាននៃការលូតលាស់របស់ដំណាំពោត

ធ្វើការតាមដានលទ្ធផល (ទិន្នផល )

ធ្វើការតាមដានសត្វល្អិត និងជម្ងឺបំផ្លាញដំណាំ

រកដោះស្រាយបញ្ហាដែលកើតមានភ្លាមៗ

## ៥.វិធីសាស្រ្តអនុវត្តន៍

- ការរៀបចំដី (ភ្ជួរដី២ដង)
- ហាលដី រយះពេល ៧ថ្ងៃ
- លើករង ទទឹង១ម
- ដាក់ជីទ្រាប់បាត
- ដាក់ជីបំប៉នលើកទី៣លើក

**៦-អ្នកទទួលខុសត្រូវ**

**មន្ទីរកសិកម្មខេត្តស្វាយរៀង ក្រុមការងារប្រូលីណូវ៉ាំដែលអនុវត្តន៍មាន ចំនួន ០២រូប ក្នុងនោះ ៖**

១-លោកស្រី **ពៅ ធីតា** អនុប្រធានមន្ទីរកសិកម្មខេត្ត និងជាប្រធានសម្របសម្រួលកម្មវិធីប្រូលីណូវ៉ាំថ្នាក់ខេត្ត ។

២- លោក **សំ ឈឿន** មន្រ្តីការិយាល័យផ្សព្វផ្សាយកសិកម្ម និងជាមន្រ្តីសម្របសម្រួលបច្ចេកទេស និងជាទទួលបន្ទុក បណ្តុះបណ្តាល និងគណនេយ្យ ។